**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៥៧ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ចំណាត់ថ្នាក់សំណង់ និងគោលដៅ ដែលតម្រូវឱ្យមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់
- បានឃើញព្រះរាជក្រមលេខ ០៨/នស/៩៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំដែនដីនគរូបនីយកម្មនិងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៣/០០៧ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្ការ និងការពន្លត់អគ្គិភ័យ

- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះមានគោលបំណងកំណត់អំពីចំណាត់ថ្នាក់សំណង់ និងគោលដៅដែលតម្រូវឱ្យមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ ដើម្បីការពារទប់ស្កាត់គ្រោះថ្នាក់អគ្គិភ័យ។

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីសមត្ថកិច្ចគ្រប់គ្រង ត្រួតពិនិត្យលើប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យនៃសំណង់ និងគោលដៅ ដើម្បីបង្ការ និងការពារអាយុជីវិត ទ្រព្យសម្បត្តិ បរិស្ថាន សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គមពីគ្រោះថ្នាក់អគ្គិភ័យ។

**មាត្រា៣ .-**

អនុក្រឹត្យនេះមានវិសាលភាពគ្របដណ្តប់លើសំណង់ និងគោលដៅ ដែលតម្រូវឱ្យមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៤ .-**

វាក្យស័ព្ទសំខាន់ៗដែលមានប្រើក្នុងច្បាប់ស្តីពីការបង្ការ និងការពន្លត់អគ្គិភ័យត្រូវបានបន្ថែមក្នុងអនុក្រឹត្យនេះមាននិយមន័យដូចខាងក្រោម ៖

- អគ្គិភ័យ សំដៅដល់ករណីមានភ្លើងឆេះមិនអាចគ្រប់គ្រងបានដែលអាចបង្កមហន្តរាយដល់អាយុជីវិត ទ្រព្យសម្បត្តិ និងបរិស្ថាន។
- ការបង្ការអគ្គិភ័យ សំដៅដល់ការរៀបចំអនុវត្តនូវលក្ខខណ្ឌ និងវិធានការនានាដើម្បីធានាសុវត្ថិភាពមិនឱ្យមានអគ្គិភ័យកើតឡើង។
- ចំណាត់ថ្នាក់សំណង់ សំដៅដល់សំណង់ដែលត្រូវបានកំណត់ឱ្យមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យដូចមានចែងក្នុងអនុក្រឹត្យនេះ។
- គោលដៅ សំដៅដល់ទីកន្លែងនានា និងមធ្យោបាយដឹកជញ្ជូនទាំងឡាយដែលអាចមានអគ្គិភ័យកើតឡើង។
- ប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ សំដៅដល់គំនូរទាំងឡាយដែលត្រូវបានកំណត់យ៉ាងច្បាស់ និងលម្អិតអំពីការបំពាក់ឧបករណ៍ សម្ភារៈ បរិក្ខារសម្រាប់ការបង្ការ និងការពន្លត់អគ្គិភ័យ។

- ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ សំដៅដល់ការបំពាក់ឧបករណ៍បច្ចេកទេសក្នុង និង/ឬក្រៅសំណង់ និងគោលដៅ និងវិធានការនានាដើម្បីបង្ការ ទប់ស្កាត់ ពន្លត់អគ្គិភ័យ និងសង្គ្រោះ។

- មធ្យោបាយ សំដៅដល់យានយន្ត ឧបករណ៍ សម្ភារៈ បរិក្ខារដែលប្រើប្រាស់សម្រាប់បង្ការ និងពន្លត់អគ្គិភ័យ។

## ជំពូកទី ២

## សមត្ថកិច្ចគ្រប់គ្រង និងត្រួតពិនិត្យ

**មាត្រា៥ .-**

ក្រសួងមហាផ្ទៃមានសមត្ថកិច្ច៖

- ត្រួតពិនិត្យប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យលើរាល់សំណង់ និងគោលដៅឱ្យបានត្រឹមត្រូវស្របតាមបទដ្ឋានបច្ចេកទេស

- ត្រួតពិនិត្យឧបករណ៍ សម្ភារៈ បរិក្ខារសម្រាប់បំពាក់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យឱ្យស្របតាមបទដ្ឋានបច្ចេកទេស

- ត្រួតពិនិត្យទីតាំងស្តុក ដាក់លក់ឧបករណ៍ សម្ភារៈ បរិក្ខាបង្ការ និងពន្លត់អគ្គិភ័យ

- បញ្ជាក់ទទួលស្គាល់លើគំនូរប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ

-ចេញលិខិតផ្អាកសកម្មភាពបណ្តោះអាសន្នដល់ផ្នែកណាមួយនៃសំណង់ និងគោលដៅ ដែលខ្វះលក្ខខណ្ឌ និងវិធានការបង្ការ និងពន្លត់អគ្គិភ័យ។

**មាត្រា៦ .-**

ចំពោះតម្រូវការត្រួតពិនិត្យលើប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ រាល់សំណង់ និងគោលដៅដែលជាមូលដ្ឋានកងទ័ព ឬគោលដៅរក្សាការសម្ងាត់ទាក់ទងនឹងសន្តិសុខជាតិ ឬក្នុងស្ថានទូត ស្ថានកុងស៊ុល ស្ថានតំណាងបរទេស និវេសនដ្ឋាន ឬស្ថានតំណាងអង្គការអន្តរជាតិ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាមីពាក់ព័ន្ធ។ ក្នុងករណីមានសំណើពីក្រសួងសាមីពាក់ព័ន្ធ អង្គភាពបង្ការ និងពន្លត់អគ្គិភ័យនៃក្រសួងមហាផ្ទៃ អាចជួយគាំទ្រលើផ្នែកបច្ចេកទេសបាន។

**មាត្រា៧ .-**

ក្រសួងមហាផ្ទៃធ្វើប្រតិភូកម្មអំណាចដល់អគ្គស្នងការដ្ឋាននគរបាលជាតិ និងស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ដើម្បីគ្រប់គ្រង និងត្រួតពិនិត្យលើប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យរាល់សំណង់ និងគោលដៅដែលតម្រូវឱ្យមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យដូចមានចែងក្នុងមាត្រា៥ នៃអនុក្រឹត្យនេះ។

**មាត្រា៨ .-**

ក្រសួងមហាផ្ទៃ អាចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូជំនាញផ្នែកបច្ចេកទេសប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ សំដៅលើកកម្ពស់វិជ្ជាជីវៈ និងបច្ចេកទេសនៃការត្រួតពិនិត្យប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ។

**មាត្រា៩ .-**

មន្ត្រីនគរបាលបង្ការ និងពន្លត់អគ្គិភ័យដែលចុះត្រួតពិនិត្យលើសំណង់ និងគោលដៅ ត្រូវបង្ហាញបណ្ណសម្គាល់ខ្លួន សញ្ញាសម្គាល់ និងលិខិតបញ្ជាបេសកកម្ម ជូនម្ចាស់សំណង់ ឬជនដែលខ្លួនត្រូវទំនាក់ទំនង និងត្រូវមានកំណត់ហេតុត្រឹមត្រូវច្បាស់លាស់។

មាត្រា១០ .-

រយៈពេល និងកម្រៃសេវានៃការផ្ដល់លិខិតបញ្ជាក់ទទួលស្គាល់ប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួង រវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

បែបបទ និងនីតិវិធីក្នុងការបញ្ជាក់ទទួលស្គាល់ប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

មាត្រា១១ .-

អគ្គស្នងការដ្ឋាននគរបាលជាតិ ឬស្នងការដ្ឋាននគរបាលរាជធានី ខេត្ត មានសមត្ថកិច្ចចេញលិខិតព្រមាន និងពិន័យអន្តរការណ៍ចំពោះម្ចាស់សំណង់ និងម្ចាស់គោលដៅទាំងឡាយណាដែលបំពាក់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យមិនត្រឹមត្រូវស្របតាមបទដ្ឋានបច្ចេកទេស ឬមិនបានបំពាក់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យដូចមានកំណត់ក្នុងអនុក្រឹត្យនេះ។

## ជំពូកទី ៣
## ចំណាត់ថ្នាក់សំណង់ និងគោលដៅដែលតម្រូវឱ្យមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ

មាត្រា១២ .-

សំណង់ និងគោលដៅដែលតម្រូវឱ្យមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ ត្រូវបានកំណត់ចំណាត់ថ្នាក់ដូចខាងក្រោម៖

ក-ចំណាត់ថ្នាក់ទី១ : សំណង់ ឬគោលដៅពាណិជ្ជកម្មទាក់ទងនឹងការផលិត ការលក់ ការកែច្នៃ ការស្តុកស្តានីយប្រេង និងការប្រើប្រាស់ឧស្ម័នចំហេះ សារធាតុងាយឆេះ ងាយផ្ទុះ និងងាយផ្ទុះឆេះ។

ខ-ចំណាត់ថ្នាក់ទី២ : ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពរបស់រដ្ឋ គ្រឹះស្ថានសាធារណៈ និងឯកជន។

គ-ចំណាត់ថ្នាក់ទី៣ : សំណង់ ឬគោលដៅនៃទីប្រជុំជនដែលមានប្រជាជនរស់នៅច្រើនកុះករ អគារសហកម្មសិទ្ធិ បុរីលំនៅឋាន ឬលំនៅឋានមានលក្ខណៈបុរី បណ្តុំអគារពាណិជ្ជកម្មធំៗ រោងភាពយន្ត រោងមហោស្រព សារមន្ទីរជាតិ បណ្ណសារជាតិ បណ្ណាល័យជាតិ ទីកន្លែងសប្បាយកាព ក្លឹបកំសាន្ត ស្ថានីយវិទ្យុ ស្ថានីយទូរទស្សន៍ ស្ថានីយទូរគមនាគមន៍ ក្រុមហ៊ុនគោលដៅស្រាវជ្រាវវិទ្យាសាស្ត្រ អាកាសយានដ្ឋាន ស្ថានីយរាជាយស្ម័យយាន កំពង់ផែ យានដ្ឋាន និងចំណតយានយន្ត។

ឃ-ចំណាត់ថ្នាក់ទី៤ : សំណង់ ឬគោលដៅដែលស្ថិតនៅតំបន់ភ្នំ តំបន់ព្រៃ តំបន់អភិរក្ស ឃលីយដ្ឋាន ស្ថានីយអគ្គិសនី វារីអគ្គិសនី រោងចក្រ សហគ្រាស ឧស្សាហកម្ម សិប្បកម្ម និងការដ្ឋានរ៉ែ។

ង-ចំណាត់ថ្នាក់ទី៥ : អគារពាណិជ្ជកម្មខ្នាតតូច និងផ្សារ។

មាត្រា១៣ .-

សំណង់ និងគោលដៅដែលតម្រូវឱ្យមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ ស្ថិតក្រោមសមត្ថកិច្ចរបស់អគ្គស្នងការដ្ឋាននគរបាលជាតិ៖

ក-សំណង់ និងគោលដៅទាំងឡាយណាដែលមានផ្ទៃក្រឡាកម្រាលចាប់ពី ៣.០០០(បីពាន់)ម៉ែត្រក្រឡា និង/ឬ មានកម្ពស់ចាប់ពី ៩(ប្រាំ)ជាន់ឡើង ដោយរាប់បញ្ចូលទាំងជាន់ក្រោមដី និង/ឬផ្ទុកចំនួនមនុស្សចាប់ពី ២០០(ពីររយ)នាក់ និង/ឬចំនួនបន្ទប់ចាប់ពី ២៥(ម្ភៃប្រាំ)បន្ទប់ និង/ឬចំណតរថយន្តចាប់ពី ១០០(មួយរយ)គ្រឿង។

ខ-ស្ថានីយប្រេងឥន្ធនៈ ដេប៉ូប្រេង ពោងស្តុកប្រេងឥន្ធនៈ ទីតាំងលក់ឧស្ម័នចំហេះ និងគោលដៅផលិត កែច្នៃសារធាតុងាយផ្ទុះ ងាយឆេះ និងងាយផ្ទុះឆេះគ្រប់ប្រភេទ ចំណុះចាប់ពី ១០.០០០(មួយម៉ឺន)លីត្រ និង/ឬ ៥.០០០ (ប្រាំពាន់)គីឡូក្រាមឡើង។

គ-សំណង់សំខាន់ៗក្នុងតំបន់ការពារបរិស្ថានធម្មជាតិ បេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្ត្រ រមណីយដ្ឋាន ទេសចរណ៍ និងសាសនា។

**មាត្រា១៤ .-**

សំណង់ និងគោលដៅដែលតម្រូវឱ្យមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ ស្ថិតក្រោមសមត្ថកិច្ចរបស់ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត៖

ក-សំណង់ និងគោលដៅទាំងឡាយណាដែលមានផ្ទៃក្រឡាកម្រាលក្រោម ៣.០០០(បីពាន់)ម៉ែត្រក្រឡា និង/ឬមានកម្ពស់ ៤(បួន)ជាន់ចុះ ដោយរាប់បញ្ចូលទាំងជាន់ក្រោមដី និង/ឬផ្ទុកចំនួនមនុស្សក្រោម ២០០(ពីររយ)នាក់ និង/ឬចំនួនបន្ទប់ក្រោម ២៥(ម្ភៃប្រាំ)បន្ទប់ និង/ឬចំណតរថយន្តក្រោម ១០០(មួយរយ)គ្រឿង

ខ-ស្ថានីយប្រេងឥន្ធនៈ ដេប៉ូប្រេង ពោងស្តុកប្រេងឥន្ធនៈ ទីតាំងលក់ឧស្ម័នចំហេះ និងគោលដៅផលិត កែច្នៃសារធាតុងាយផ្ទុះ ងាយឆេះ និងងាយផ្ទុះឆេះគ្រប់ប្រភេទ ចំណុះក្រោម ១០.០០០(មួយម៉ឺន)លីត្រ និង/ឬ ៥.០០០(ប្រាំពាន់)គីឡូក្រាម។

**មាត្រា១៥ .-**

ចំពោះសំណង់ និងគោលដៅដែលពាក់ព័ន្ធដល់រោងចក្រ សហគ្រាសធុនតូច មធ្យម និងសិប្បកម្មដែលបានចំណាត់ថ្នាក់ដូចខាងលើ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ។

ចំពោះការអនុញ្ញាត ឬបញ្ជាក់ប្លង់សុវត្ថិភាពបច្ចេកទេសឧស្សាហកម្ម និងសិប្បកម្ម ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការគ្រប់គ្រង រោងចក្រ និងសិប្បកម្ម។

## ជំពូកទី ៤

## ភារកិច្ចរបស់ម្ចាស់សំណង់ ឬម្ចាស់គោលដៅ

**មាត្រា១៦ .-**

ម្ចាស់សំណង់ ឬម្ចាស់គោលដៅ ត្រូវមានគំនូរប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ និងមានការបញ្ជាក់ទទួលស្គាល់ពីអគ្គស្នងការដ្ឋាននគរបាលជាតិ ឬស្នងការដ្ឋាននគរបាលរាជធានី ខេត្ត មុនដំណើរការសាងសង់។

គំនូរប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យត្រូវបានសិក្សា និងគូរដោយអ្នកជំនាញមានវិជ្ជាជីវៈ និងមានការទទួលស្គាល់ដោយស្ថាប័នមានសមត្ថកិច្ច។

ម្ចាស់សំណង់ ឬម្ចាស់គោលដៅ ចាំបាច់ត្រូវទទួលបានលិខិតបញ្ជាក់បញ្ចប់ការរៀបចំប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យទទួលស្គាល់ពីអគ្គស្នងការដ្ឋាននគរបាលជាតិ ឬស្នងការដ្ឋាននគរបាលរាជធានី ខេត្ត។

បែបបទ និងនីតិវិធីនៃការស្នើសុំរបស់ម្ចាស់សំណង់ និងម្ចាស់គោលដៅ ដូចមានចែងក្នុងមាត្រា១៦ នេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា១៧ .-**

ម្ចាស់សំណង់ ឬម្ចាស់គោលដៅមុនការប្រើ និងជួសជុល កែតម្រូវទៅលើប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យត្រូវស្នើសុំលិខិតអនុញ្ញាតពីអគ្គស្នងការដ្ឋាននគរបាលជាតិ ឬស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ដូចមានចែងក្នុងមាត្រា១៣ មាត្រា១៤ និងមាត្រា១៥ នៃអនុក្រឹត្យនេះ។

## ជំពូកទី ៥

## ទោសប្បញ្ញត្តិ

**មាត្រា១៨ .-**

នីតិវិធីនៃការពិន័យអន្តរការណ៍ ការបង់ប្រាក់ពិន័យ ការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ពិន័យ និងការចាត់ចែងប្រាក់ចំណូលដែលបានមកពីការពិន័យចំពោះបទល្មើសដូចមានចែងក្នុងអនុក្រឹត្យនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួង រវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

នីតិវិធីនៃការចាត់ចែងប្រាក់ពិន័យដែលបានមកពីការផ្តន្ទាទោសដោយតុលាការ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួង រវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

**មាត្រា១៩ .-**

មន្ត្រីនគរបាលបង្ការ និងពន្លត់អគ្គិភ័យ រូបណាដែលធ្វេសប្រហែស ខកខាន ឬធ្វើជាភ្លេចភ្លាំង ខ្វះការទទួលខុសត្រូវ មិនបានបំពេញភារកិច្ចត្រឹមត្រូវ ដូចមានចែងក្នុងអនុក្រឹត្យនេះ ត្រូវទទួលទណ្ឌកម្មផ្នែករដ្ឋបាល។ ក្នុងករណីធ្ងន់ធ្ងរត្រូវទទួលទោសតាមច្បាប់ជាធរមាន។

**មាត្រា២០ .-**

នីតិបុគ្គល ឬរូបវន្តបុគ្គល ដែលជាម្ចាស់សំណង់ ឬម្ចាស់គោលដៅ មិនគោរពអនុវត្តតាមបទប្បញ្ញត្តិដូចមានចែងក្នុងអនុក្រឹត្យនេះត្រូវៈ

- ព្រមានជាលាយលក្ខណ៍អក្សរ
- ក្នុងករណីមិនអនុវត្តតាមការព្រមានជាលាយលក្ខណ៍អក្សរ ត្រូវពិន័យអន្តរការណ៍ជាប្រាក់មិនលើសពី ១០.០០០.០០០ (ដប់លាន)រៀល
- ក្នុងករណីនៅតែមិនព្រមអនុវត្ត ត្រូវប្តឹងទៅតុលាការសុំផ្អាកការសាងសង់ជាបណ្តោះអាសន្ន។

**មាត្រា២១ .-**

ម្ចាស់សំណង់ និងម្ចាស់គោលដៅ មិនបានអនុវត្តស្របតាមប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ ដែលមានក្នុងគំនូរប្លង់សាងសង់រួម ត្រូវព្រមានជាលាយលក្ខណ៍អក្សរ។ ក្នុងករណីមិនអនុវត្តតាមការព្រមានជាលាយលក្ខណ៍អក្សរ ត្រូវពិន័យជាប្រាក់ ពី ២.០០០.០០០(ពីរលាន)រៀល ទៅ ៥.០០០.០០០(ប្រាំលាន)រៀល និងតម្រូវឱ្យធ្វើការកែតម្រូវឱ្យស្របតាមប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យជាមុនសិន។

**មាត្រា២២ .-**

ម្ចាស់សំណង់ និងម្ចាស់គោលដៅដំណើរការសាងសង់គ្មានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ និងមិនមានការបញ្ជាក់ទទួលស្គាល់ពីអគ្គស្នងការដ្ឋាននគរបាលជាតិ ឬស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ត្រូវផ្អាកសកម្មភាពជាបណ្តោះអាសន្ន និងត្រូវពិន័យជាប្រាក់មិនលើសពី ១០.០០០.០០០(ដប់លាន)រៀល។

ក្នុងករណីមិនរៀងចាល ត្រូវពិន័យជាប្រាក់ទ្វេរដង។

**មាត្រា២៣ .-**

ម្ចាស់សំណង់ និងម្ចាស់គោលដៅដែលធ្វើការរុះរើ ជួសជុល ឬកែតម្រូវប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យមិនបានសុំការអនុញ្ញាតជាមុន ត្រូវព្រមានជាលាយលក្ខណ៍អក្សរ។ ក្នុងករណីមិនរៀងចាលត្រូវពិន័យជាប្រាក់ពី ២.០០០.០០០(ពីរលាន)រៀល ទៅ ៥.០០០.០០០(ប្រាំលាន)រៀល។

**មាត្រា២៤ .-**

ការបង់ប្រាក់ពិន័យអន្តរការណ៍នាំឱ្យរលត់បណ្តឹងអាជ្ញា។

## ជំពូកទី ៦

## អន្តរប្បញ្ញត្តិ

**មាត្រា២៥ .-**

ក្នុងរយៈពេល ២៤ខែ បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន ម្ចាស់សំណង់ និងម្ចាស់គោលដៅដែលបានសាងសង់រួច ឬកំពុងដំណើរការសាងសង់ពុំមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ ត្រូវមកបំពេញបែបបទស្នើសុំលិខិតបញ្ជាក់ ពីអគ្គស្នងការដ្ឋាននគរបាលជាតិ ឬស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ស្របតាមអនុក្រឹត្យនេះ។

## ជំពូកទី ៧

## អវសានប្បញ្ញត្តិ

**មាត្រា២៦ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២៧ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវទទួលអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

*ថ្ងៃ ... ខែ ... ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២*
*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ... ខែ ធ្នូ ឆ្នាំ ២០១៨*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ជា សុផារ៉ា**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ២៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ